**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

សំណុំរឿងព្រហ្មទណ្ឌលេខ:៧១៤

ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៧

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ១៥ (ច)

ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០១៨

**តាងនាមប្រជារាស្ត្រខ្មែរ**

*សាលាដំបូងខេត្តកំពង់ឆ្នាំង បានបើកសវនាការ*

ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៨

*ដោយមានសមាសភាពជំនុំជម្រះ៖*

១-លោក [redacted] *ចៅក្រមជំនុំជម្រះ*

២-លោក [redacted] *តំណាងអយ្យការ*

៣-លោក [redacted] *ក្រឡាបញ្ជីសវនាការ*

*ដើម្បីធ្វើការជំនុំជម្រះលើជនជាប់ចោទ:*

១-ឈ្មោះ: [redacted] (បារាំង) ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិទ្រាជើង ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ទីកន្លែងសព្វថ្ងៃនៅភូមិក្តីត្នោត ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ[redacted]) ម្តាយឈ្មោះ: [redacted] ប្រពន្ធឈ្មោះ: [redacted] គ្មានកូន ទោសពីមុនមាន (ឃុំខ្លួនថ្ងៃទី ខែ ឆ្នាំ២០១៧) ។

ត្រូវជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទ្រាត្បូង ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:**

កាលពីថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១១និង ៣០នាទី នៅចំណុចភូមិទ្រាត្បូង ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង សមត្ថកិច្ចនគរបាលនៃការិយាល័យនគរបាលប្រឆាំងគ្រឿងញៀនបានធ្វើតេស្តទឹកនោមលើឈ្មោះ[redacted](បារាំង) រកឃើញសារធាតុញៀននៅក្នុងខ្លួន ក្រោយពីធ្វើការសាកសួរលើឈ្មោះ[redacted] (បារាំង) បានសារភាពថាខ្លួនធ្លាប់ជាប់ពន្ធនាគារចំនួន ០៦ខែ ពីបទ:ប្រើប្រាស់សារធាតុញៀនដោយខុសច្បាប់ ហើយឈ្មោះ:[redacted](បារាំង) បានឆ្លើយថាថ្នាំញៀនដែលខ្លួនយកមកប្រើប្រាស់នេះគឺបានទិញពីឈ្មោះ[redacted] បានឆ្លើយថាថ្នាំញៀនដែលខ្លួនយកមកប្រើប្រាស់នេះទិញពីឈ្មោះ[redacted]ភេទប្រុស រស់នៅភូមិព្រៃខ្មែរ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំនួន ០៧ដង។



Scanned by CamScanner

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ២២១ /១៨ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៦៩ /១៨ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ១៩០ /១៨ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៨ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

## នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា: កាលពីថ្ងៃកើតហេតុ ឈ្មោះ[redacted]បានប្រើឲ្យខ្លួនទៅទិញគ្រឿងញៀន ដោយប្រាក់គេជាអ្នកឲ្យ ខ្លួនទិញបានចំនួន ៨០.០០០(ប៉ែតសិបពាន់)រៀល យកទៅឲ្យគេបានចំនួន ០៣ដង កន្លងមកហើយ ពេលទិញបានយកមកឲ្យគាត់ហើយ គាត់បានដកឲ្យខ្លួនសម្រាប់ជក់ ។

-ចម្លើយមន្ត្រីនគរបាលឈ្មោះ[redacted] បានឆ្លើយថា: កាលពីថ្ងៃកើតហេតុ កម្លាំងបានចុះទៅធ្វើល្បាត នៅពេលយប់ ពេលសាកសួរទើបដឹងថាទិញគ្រឿងញៀនពីឈ្មោះ[redacted]ដោយប្រើប្រាស់កម្លាំងជាធ្លាក់ទៅទិញ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ[redacted]បានសំណូមពរចុងក្រោយថា: សូមឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយមន្ត្រីនគរបាលយុត្តិធម៌
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យ ភស្តុតាង ឯកសារទាំងអស់ក្នុងសំណុំរឿង
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សាលាដំបូងខេត្តកំពង់ឆ្នាំង យល់ឃើញថា:</u>

១-តុលាការបានទទួលបណ្តឹងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៦៩ /១៨ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានបញ្ជូនជនជាប់ចោទ ១-ឈ្មោះ[redacted] មកតុលាការដើម្បីជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិក្តីត្នោត ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned by CamScanner

២-ចម្លើយជនជាប់ចោទឈ្មោះ[redacted]ថា: កាលពីថ្ងៃកើតហេតុ ខ្លួនបានទៅទិញគ្រឿងញៀនឲ្យទៅឈ្មោះ[redacted]ដោយគេឲ្យគ្រឿងញៀនឲ្យខ្លួនទុកសម្រាប់ជក់ ។

៣-ចម្លើយមន្ត្រីនគរបាលឈ្មោះ[redacted]: កាលពីថ្ងៃកើតហេតុ កម្លាំងបានទៅធ្វើវដ្តបាល នៅពេលយប់ ពេលសាកសួរទើបដឹងថាទិញគ្រឿងញៀនពីឈ្មោះ[redacted]ដោយប្រើប្រាស់កម្លាំងជាផ្ទាក់ទៅទិញ ។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ[redacted]ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់ ការប្តឹងសុំនេះតុលាការអាចពិចារណាព្រោះតាមអង្គហេតុ ពេលកម្លាំងនគរបាលប្រើប្រាស់ផ្ទាក់ដើម្បីទិញគ្រឿងញៀនពីជនជាប់ចោទបាន ដូច្នេះអំពើនេះជាការជួញដូរគ្រឿងញៀនយ៉ាងពិតប្រាកដ ។

៥-ឆ្លងកាត់សវនាការ ការពិភាក្សាដេញដោល ចម្លើយជនជាប់ចោទ ចម្លើយមន្ត្រីជំនាញ ការប្តឹងសុំរបស់តំណាងអយ្យការ ព្រមទាំងភស្តុតាងនានាក្នុងសំណុំរឿងតុលាការពិចារណាឃើញថាជនជាប់ចោទជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពិតប្រាកដមែន ព្រោះបើតាមអង្គហេតុទោះបីជាជនជាប់ចោទព្យាយាមបដិសេធ ប៉ុន្តែពេលប្រតិបត្តិការកម្លាំងសមត្ថកិច្ចបានប្រើផ្ទាក់ទិញគ្រឿងញៀនបានពីជនជាប់ចោទ ដូច្នេះអំពើនេះជាការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។

៦-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទ:

-ឈ្មោះ[redacted]ភេទប្រុស អាយុ ២៤ ឆ្នាំ ។

ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងស្បូង ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧-វត្ថុតាងរួមមាន:

-ទូរស័ព្ទដៃចំនួន ០២ គ្រឿង និងម៉ូតូម៉ាកវីវ៉ា ពណ៌ខ្មៅ ពាក់ស្លាកលេខកំពង់ឆ្នាំង ១អា០២៩៧ គប្បីតុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។

៨-ជនជាប់ចោទជានីតិជន ដែលមិនមានភស្តុតាងបញ្ជាក់ថាកើតមានវិបល្លាសស្មារតីទេ ដូច្នេះជននេះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ បំផ្លាញដល់សុខភាពខ្លួនឯងផ្ទាល់ ប៉ះពាល់ដល់ជីវភាពគ្រួសារ និងឈានដល់ការបង្កការលំបាកជាច្រើនទៀតដល់សង្គមជាតិ ដែលកើតឡើងដោយសារធាតុឥទ្ធិពលនៃគ្រឿងញៀន ។

## **ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសជនជាប់ចោទ:

-ឈ្មោះ[redacted]ភេទប្រុស អាយុ ២៤ ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៣(បី) ឆ្នាំ ។



Scanned by CamScanner

ពីបទៈជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទ្រាត្បូង ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុតាងរូមមានៈ ទូរស័ព្ទដៃចំនួន ០២ គ្រឿង និងម៉ូតូម៉ាកវីវ៉ា ពណ៌ខ្មៅ ពាក់ស្លាកលេខកំពង់ឆ្នាំង ១អា ០២៩៧ តុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]



Scanned by CamScanner